# វប្បធម៌តន្ត្រីប្រហែលគ្នារវាងខ្មែរនិងចាម

ចម្ប៉ា ជាប្រទេសមួយដែលគេបានបំភ្លេចចោល។ ពីសតវត្សទី១ដល់ទី២ សមុទ្រចិនខាងត្បូងមានឈ្មោះដើមថា សមុទ្រចម្ប៉ា យកឈ្មោះតាមនាវិកក្លាហាន ដែលមានទំនាក់ទំនងពាណិជ្ជកម្មជាមួយប្រទេសជាច្រើននៅទ្វីបអាស៊ី។ តាមកស្តុតាងបុរាណវិទ្យា យើងអាចធ្វើការសន្និដ្ឋានថានាវិកទាំងនេះ មកពីកោះនៃឥណ្ឌូនេស៊ី។ គ្រឿងអលង្ការដែលបានរកឃើញក្នុងផ្នូរ បង្ហាញថានាវាពាណិជ្ជកម្មរបស់គេបានធ្វើដំណើររហូតទៅដល់ច្រាំងនៃបញ្ចឹមបូព៌ា។ កំទេចសេសសល់នៃការតាំងទីលំនៅរបស់ជនជាតិចាម ដែលមានកាលបរិច្ឆេទក្នុងសតវត្សទី២ ត្រូវបានគេឃើញនៅតាមច្រាំងនៃទន្លេធំៗនៅអាស៊ីអាគ្នេយ៍ ដែលតាមរយៈទីតាំងនោះហើយ ដែលពួកគេដឹកជញ្ជូនទំនិញពីកំពង់ផែសមុទ្រ។ នៅក្នុងតំបន់ដែលមានកោះរាប់ពាន់ចន្លោះប្រទេសអូស្ត្រាលីនិងជប៉ុន ចាមជាមហាអំណាចដែលមានឥទ្ធិពលខ្លាំងបំផុតដោយគ្រប់គ្រងផ្លូវពាណិជ្ជកម្មដោយកងនាវាដ៏ខ្លាំងក្លារបស់ខ្លួន។

ពីសតវត្សទី២ប្រជាជនចាមចាប់ផ្តើមតាំងទីលំនៅនៅតាមឆ្នេរ នៃប្រទេសវៀតណាម ហើយទាញយកអំណាចនយោបាយពីអ្នកម្ចាស់ស្រុកបន្តិចម្តងៗ។ មិនយូរប៉ុន្មានពួកគេបានបាត់បង់ទំនាក់ទំនងជាមួយមាតុភូមិរបស់ពួកគេ គឺកោះឥណ្ឌូនេស៊ី។ ជនជាតិចាមបានប្រើប្រាស់អំណាចនាវាដ៏ខ្លាំងក្លារបស់ខ្លួន ក្នុងការកសាងនគរចម្ប៉ានៅកណ្តាលប្រទេសវៀតណាម។ នៅចំណុចកំពូលនៃអំណាចរបស់ចាម ចម្ប៉ាជាមហាអំណាចដ៏សំខាន់មួយក្នុងអាស៊ីអាគ្នេយ៍ ក្នុងអំឡុងពេលជាង ១,០០០ឆ្នាំ ចន្លោះ គ.ស. ៥០០ ដល់ ១៥០០។

ប្រាសាទចាមដែលត្រូវបានគេស្គាល់ជាងគេនោះ គឺប្រាសាទមីសុន ដែលមានទីតាំងមិនឆ្ងាយប៉ុន្មានពីខេត្តដាណាង និងទីក្រុងហូយអាននៃខេត្តខាងណាំ នៅប្រទេសវៀតណាមកណ្តាល។

នគរចម្ប៉ាចាប់ផ្តើមដួលរលំនៅឆ្នាំ១៤៧១ បន្ទាប់ពីការវាយប្រហារដោយរាជវង្សឡឺ ដែលគ្រប់គ្រងនៅភាគខាងជើងវៀតណាម។ ការឈ្លានពាននេះ បានធ្វើឱ្យនគរចម្ប៉ាបាក់បែក។ នៅឆ្នាំ១៨៣២ អធិរាជ មិញ ម៉ាង នៃរាជវង្សង្វៀន បានដាក់សម្ព័ន្ធមហារដ្ឋចាមចុង

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ក្រោយ។ នេះបានធ្វើឱ្យនគរចម្ប៉ាឈានមកដល់ចំណុចបញ្ចប់ ដែលនគរមួយនេះធ្លាប់ជានគរដែលគ្រងអំណាចនៅសមុទ្រចិនខាងត្បូង។ ជនជាតិចាមមួយចំនួន ជាពិសេសអ្នកកាន់សាសនាឥស្លាម បានធ្វើចំណាកស្រុកទៅប្រទេសម៉ាឡេស៊ី និង ឥណ្ឌូនេស៊ី។ ជនជាតិចាមជាច្រើនទៀត គឺរស់នៅតាមដងច្រាំងនៃទន្លេមេគង្គ ដែលក្នុងនោះគឺមានប្រជាជនជាច្រើនដែលរស់នៅក្នុងប្រទេសកម្ពុជា។ ជនជាតិចាមខ្លះ បានរស់នៅប្រទេសកម្ពុជា តាំងពីពេលដែលនគរចម្ប៉ាឈ្លានពានអង្គរម្ដេះ។

ប្រវត្តិសាស្ត្រហាក់បានបង្ហាញថា នគរចម្ប៉ាកកើតឡើងដោយមិនមានប្រភពប្រាកដ ហើយរលាយទៅវិញ ដូចជានគរនេះពុំធ្លាប់មានវត្តមានមកពីមុនដែរ។ ជនជាតិចាមនិងនគរចម្ប៉ា បានបន្សល់ទុកនូវសម្បត្តិវប្បធម៌សម្បូណ៌បែប ដែលក្នុងនោះមានវត្ថុបុរាណ ប្រាសាទ និងវិមានដែលមាននៅក្នុងប្រទេសវៀតណាម។

នៅប្រទេសកម្ពុជា មានបណ្តុំនៃសហគមន៍ជនជាតិចាម ជាពិសេសនៅជាយក្រុងនៃរាជធានីភ្នំពេញ និងក្នុងខេត្តកណ្ដាល កំពង់ស្ពឺ ពោធិ៍សាត់ កំពង់ធំ កំពង់ឆ្នាំង និងកំពង់ចាម។

អត្ថបទនេះ ផ្ដោតទៅលើវប្បធម៌តន្ត្រីចាម ដែលខ្ញុំបានសង្កេតឃើញផ្ទាល់នៅក្នុងមហោស្រពតន្ត្រីអាស៊ាន ដែលបានប្រារព្ធឡើងពីថ្ងៃទី១៩ដល់២៤ ខែធ្នូ ឆ្នាំ២០២២ នៅទីក្រុងហួយអាន ខេត្តខ្វាងណាំ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។ មហោស្រពនេះមានការចូលរួមដោយក្រុមតន្ត្រីនិងរបាំអាជីព១០ក្រុមពីប្រទេសវៀតណាម និងក្រុមតន្ត្រីនិងរបាំអន្តរជាតិ៤ មកពីបណ្ដាប្រទេសសមាជិកអាស៊ាន ក្នុងនោះមាន កម្ពុជា ឡាវ ម៉ាឡេស៊ី និងមីយ៉ាន់ម៉ា។

ក្រុមតន្ត្រីនិងរបាំចាម និងសហគមន៍ចាម បានប្រកាន់ជាប់នូវការរក្សាវប្បធម៌ និងប្រពៃណីរបស់គេ ទោះបីជាចម្ប៉ា គឺនគរចាមដើមនោះ សព្វថ្ងៃជាផ្នែកមួយនៃប្រទេសវៀតណាមរាប់សតវត្សមកហើយក្ដី។

គួរឱ្យចាប់អារម្មណ៍ជាពិសេសនោះ គឺភាពប្រហាក់ប្រហែលគ្នានៃវប្បធម៌រវាងខ្មែរនិងចាមដែលអត្ថបទនេះកំពុងធ្វើការបង្ហាញ។ នៅកម្ពុជា លោក ពេជ្រ ទុំក្រវិល បានលើកឡើងថា ល្ខោនយីកេខ្មែរមានឫសគល់នៅក្នុងពិធីសាសនារបស់ចាម។ ក្នុងល្ខោននោះ មានការប្រើ

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ប្រាស់ឧបករណ៍តន្ត្រីចាម រួមទាំងស្គរយីកេ។[១] ក្រុមតន្ត្រីនិងរបាំចាម ដែលចូលរួមក្នុងមហោស្រពខាងលើនេះ បានបង្ហាញ គួរឱ្យកោតសរសើរ នូវឧបករណ៍តន្ត្រីប្រកបដោយសព្វដ្ឋភាពដែលមានឧបករណ៍តន្ត្រីវៀតណាម ពិណាបន្ទះវែង និងឧបករណ៍តន្ត្រីសម័យបច្ចឹមប្រទេសមួយចំនួនដែលក្នុងនោះមាន ហ្គីតារសូឡូ ហ្គីតារបាស់ អ៊ិរក ព្រមទាំងស្គរខ្សែស័ង្ខ ខ្លុយឫស្សី ទ្រខ្សែពីរ ស្គរមុខពីរ ស្គរភ្ជោះ ស្គរធំ ឧបករណ៍ក្រឡុកមានគ្រាប់នៅខាងក្នុង និងស្គរយីកេដែលដូចគ្នានឹងឧបករណ៍តន្ត្រីដែលខ្មែរយើងប្រើប្រាស់សព្វថ្ងៃនៅកម្ពុជា៕

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

[១] ២០០៣: ១៤៤

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង